

# ៣...២...១...ហោះហើយ!

Let's Read
The Asia Foundation



ហ្វូងតារាចំនួន១២ កំពុងតែរះនៅក្នុងលំហអាកាស។



ហ្វូងតារា គឺជាក្រុមផ្កាយជាច្រើនប្រមូលផ្តុំគ្នាបង្កើតបាន
ជារូបរាងមួយនៅលើវេហា។
ពេលខ្លះ វាមានរាងដូចជាវត្ថុ ឬសត្វ ដែលគេនិយមហៅដូចជា
ផ្កាយកូនមាន់ ផ្កាយក្រពើ ផ្កាយកូនក្រមុំ ផ្កាយខ្លាឃ្មុំ ផ្កាយតោ
ជាដើម។



តារារណបទាំង ១១ កំពុងហោះនៅក្នុងលំហអាកាស។



តារារណបជាវត្ថុដែលធ្វើចលនាជុំវិញភព ឬផ្កាយ។ ភពផែនដីមានតារារណបធម្មជាតិមួយ គឺភពព្រះចន្ទ។ តារារណបសិប្បនិម្មិតត្រូវបានបង្កើតឡើង និងបង្ហោះទៅក្នុងលំហអាកាសសម្រាប់ទំនាក់ទំនង និងការសិក្សាអំពីតារាសាស្ត្រ និងអាកាសធាតុជាដើម។



វិស្វករ ១០ នាក់កំពុងផលិតកាំជ្រួចផ្កាយរណបមួយ។



វិស្វករជាច្រើនជំនាញមានដូចជា ផ្នែកមេកានិច ផ្នែកអេឡិចត្រូនិច និងផ្នែកអគ្គិសនី ក៏បានចូលរួមក្នុងការផលិតនេះដែរ។



អ្នកវិទ្យាសាស្ត្រ ៩ នាក់កំពុងគណនាគន្លង។

អ្នកវិទ្យាសាស្ត្រជាអ្នកសិក្សាស្រាវជ្រាវថាតើតារារណបគួរបង្ហោះ
ទៅគន្លងមួយណា។



ភពចំនួន ៨ ធ្វើដំណើរជុំវិញព្រះអាទិត្យ។



ភពស្ទួលមាន ៤ គឺភពផែនដី ភពអង្គារ ភពពុធ និងភពសុក្រ រីឯភពដែលនៅខាងក្រៅ ៤ទៀត គឺភពព្រហស្បតិ៍ ភពសៅរ៍ ភពអ៊ុយរ៉ានុស និងភពណិបទូន។ ភពទាំង ៨នេះរួមគ្នាបង្កើតជាប្រព័ន្ធព្រះអាទិត្យ។

ភពព្លុយតុងធ្លាប់ជាភពទី ៩ ប៉ុន្តែ កាលពីឆ្នាំ២០០៦ សហភាពតារាសាស្ត្រដអន្តរជាតិសម្រេចថាភពព្លុយតុងមិនត្រូវបានចាត់ទុកជាភពក្នុងប្រព័ន្ធព្រះអាទិត្យនោះទេ។



ផ្កាយដុះកន្ទុយទាំង៧នេះកំពុងធ្វើដំណើរឆ្លងកាត់។



ផ្កាយដុះកន្ទុយផ្សំឡើងពីសារធាតុដូចជា ទឹកកក ថ្ម និងឧស្ម័ន។ វាធ្វើដំណើរតាមគន្លងព្រះអាទិត្យ តែភាពច្រើននៅឆ្ងាយពីភពផែនដី។ បើវាឆ្លងកាត់ផែនដី វាតែងបន្សល់ទុកនូវស្នាកស្នាមម៉្យាងរាងដូចកន្ទុយ។



មនុស្ស ៦ នាក់កំពុងមើលទៅលំហតាមរយៈកែវពង្រីក។







តេឡេស្កូបអាចជួយឱ្យយើងមើលឃើញវត្ថុដែលនៅឆ្ងាយដូចជា
តារា ភព ព្រះចន្ទ និងអាចម៍ផ្កាយជាដើម។




ភពតូចៗទាំង ៥ កំពុងបណ្តែតខ្លួនលើលំហអាកាស។



ភពតូចៗមានទំហំតូចជាងភពធម្មតា ហើយគ្មានគន្លងច្បាស់លាស់នៅជុំវិញព្រះអាទិត្យឡើយ។ នេះមានន័យថាផ្កាយព្រះគោ និងអាចម៍ផ្កាយជាដើមពុំមានគន្លងជាក់លាក់ទេ។ ភពចំនួន ៥មានដូចជាភពព្លុយតុង សេរ៉េ អេរីស ម៉ាកេម៉េក ហ៊ូមៀ ជាភពតូចៗនៅក្នុងប្រព័ន្ធព្រះអាទិត្យ។




កម្មករ ៤ នាក់កំពុងចាក់សាំងចូលកាំជ្រួចអវកាស។



ដូចគ្នានឹងរថយន្តដែរ កាំជ្រួចអវកាសក៏ត្រូវការប្រេងឥន្ធនៈ
ដើម្បីដំណើរការ។ កាំជ្រួចអវកាសត្រូវការទាំងប្រេងរាវ និងរឹង។



អវកាសយានិក ៣ រូបកំពុងស្ថិតក្នុងឈុតសម្លៀកបំពាក់
អវកាសរបស់ពួកគេ។





ឈុតសម្លៀកបំពាក់អវកាសជួយការពារអាកាសយានិកនៅក្នុងលំហ តាមរយៈការផ្ដល់ខ្យល់អុកស៊ីសែនសម្រាប់ដកដង្ហើម ទឹកសម្រាប់បរិភោគ ការពារកុំឱ្យរងា ឬក្ដៅពេក និងរក្សាសុវត្ថិភាពពីធូលីនៅក្នុងលំហអាកាសផងដែរ។




កុមារពីរនាក់កំពុងនៅក្នុងមជ្ឈមណ្ឌលគ្រប់គ្រងបេសកកម្ម។



មជ្ឈមណ្ឌលគ្រប់គ្រងបេសកម្មគឺជាបន្ទប់មួយ ដែលប្រធានក្រុមជួបប្រជុំ និងអនុវត្តការងារ ដើម្បីធានាការបង្ហោះកាំជ្រួចអវកាសប្រកបដោយជោគជ័យ និងអ្វីៗដំណើរការរលូតរហូតដល់ពេលបេសកម្មបញ្ចប់។



កាំជ្រួចអវកាសមួយកំពុងត្រៀមនឹងបង្ហោះទៅលំហអាកាស។ កាំជ្រួចអវកាសគឺជាយានយន្តមួយដែលអាចហោះឡើងទៅលំហអាកាស។ កាំជ្រួចអវកាសត្រូវបានប្រើប្រាស់ ដើម្បីបង្ហោះផ្កាយរណបទៅលំហអាកាស។



ហោះឡើងទៅហើយ...!



នៅឆ្នាំ ២០១៧ ប្រទេសឥណ្ឌាបានបំបែកឯកត្តកម្មពិភពលោក ដោយបានបង្ហោះផ្កាយរណបចំនួន ១០៤ តាមរយៈកាំជ្រួចអវកាសតែមួយគត់ ដែលមានឈ្មោះថា PSLV-C37។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*3…2…1… Blast Off*, Published by Pratham Books, © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by/4.0/
Contributing translators: Solyda Say and Nhean Socheat